រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

053KH01A-01

សកម្មភាពនៃសេចក្តីស្រឡាញ់



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៥៣

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

គោលបំណងរបស់ការសិក្សានេះ គឺធ្វើអោយសេចក្តីស្រឡាញ់នៅក្នុងក្រុមជំនុំរបស់អ្នកបានគ្រប់លក្ខណ៍ ។ សូមអធិស្ឋានទូលសូមអោយបានសំរេចគោលបំណងនេះ ។

អាន និង រិះគិតពិចារណាអំពី ១ កូរិនថូស ១៣:១-១៣ ។

យើងចាំបាច់ត្រូវមានសេចក្តីស្រឡាញ់កាន់តែខ្លាំងចំពោះ :

- ព្រះជាម្ចាស់ (ម៉ាថាយ ២២:៣៧)
- បងប្អូនយើងក្នុងព្រះគ្រីស្ត (១ យ៉ូហាន ៣:១១)
- គូស្រករបស់យើង (អេភេសូ ៥:៣៣)
- សាច់ញាតិ និង មិត្តភក្តិ (រ៉ូម ១២:១០)
- អ្នកជិតខាងរបស់យើង (ម៉ាថាយ ២២:៣៩)
- សង្គមដែលយើងរស់នៅ (រ៉ូម ១៣:១-១០)
- ខ្មាំងសត្រូវរបស់យើង (ម៉ាថាយ ៥:៤៣-៤៤) ។

កំណត់ចំណាំ :

© Project WorldReach © SEAN

សេចក្តីស្រឡាញ់

បណ្ឌិតខាងវិន័យម្នាក់ទូលសួរព្រះយេស៊ូ ក្នុងគោលបំណងរកចាប់កំហុសព្រះអង្គ (ម៉ាថាយ ២២:៣៤-៤០) ។



កំណត់ចំណាំ :

ដើម្បីអោយយើងអាចប្រតិបត្តិតាមសេចក្តីបង្គាប់គ្រប់យ៉ាង ដំបូង យើងត្រូវស្រឡាញ់ :

☐ ខ្ទាំងសត្រូវរបស់យើង ។

☐ ព្រះជាម្ចាស់ ។

បើសិនជាយើងស្រឡាញ់ព្រះជាម្ចាស់លើសអ្វីៗទាំងអស់ និង លើសមនុស្សណាទាំងអស់ នោះព្រះជាម្ចាស់នឹងជួយយើងអោយកាន់តែមានសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ ។

មាតាបិតាខ្លះភ័យខ្លាចថា បើសិនជាកូនៗគាត់ស្រឡាញ់ព្រះជា-ម្ចាស់ គេអាចនឹងឈប់ស្រឡាញ់ និង គោរពគាត់ជាមាតាបិតារបស់គេ ។ ប៉ុន្តែ សេចក្តីបង្គាប់សំខាន់ជាងគេមួយរបស់ព្រះជាម្ចាស់គីអោយយើងស្រឡាញ់មនុស្សឯទៀត ឱ្យបានដូចជាស្រឡាញ់ខ្លួនយើង ។ ព្រះជាម្ចាស់ជ្រាបដឹងថា មនុស្សបាបមិនអាចមានសេចក្តីស្រឡាញ់ពិត ចំពោះមនុស្សឯទៀតទេ ។ នៅពេលដែលយើងស្រឡាញ់ព្រះជាម្ចាស់មុនគេបង្អស់ នោះព្រះអង្គនឹងដាក់សេចក្តីស្រឡាញ់ដ៏បរិសុទ្ធមកក្នុងចិត្តយើង ហើយសេចក្តីនោះនឹងជួយឱ្យយើងអាចស្រឡាញ់មនុស្សឯទៀតបានដែរ ។ បើកូនៗពិតជាស្រឡាញ់ព្រះជាម្ចាស់ កូនៗនឹងគោរព ហើយមានចិត្តសប្បុរស

កំណត់ចំណាំ :

© Project WorldReach © SEAN

ចំពោះមាតាបិតាខ្លួន ជាងនៅពេលដែលពួកគេមិនទាន់ស្រឡាញ់ព្រះជាម្ចាស់ ។ កំហឹង និង ការច្រណែន ដែលនៅក្នុងចិត្តរបស់មនុស្ស បណ្តាលអោយមនុស្សមានទំនាស់ជាមួយមនុស្សឯទៀត ។ នៅពេលដែលមនុស្សជឿទុកចិត្តលើព្រះជាម្ចាស់ ព្រះអង្គនឹងរំលាយកំហឹង ការស្អប់ និង ការច្រណែនអស់ពីក្នុងចិត្តរបស់គេ ហើយពួកគេនឹងអាចស្រឡាញ់ និង ជួយអ្នកដទៃវិញ ។

យើងពិបាកនឹងស្រឡាញ់មនុស្សគ្រប់ប្រភេទណាស់ ។ តើយើងអាចស្រឡាញ់មនុស្សប្រមឹក ដែលវាយប្រពន្ធ វាយកូន ឬ អ្នកដែលកេងប្រវ័ញ្ចមនុស្សដែលរស់នៅក្នុងសហគមន៍ជាមួយគ្នាដែរឬទេ ? ការដែលយើងមានសេចក្តីស្រឡាញ់ចំពោះមនុស្ស មិនមែនមានន័យថា យើងពេញចិត្តនឹងអំពើបាប ដែលមនុស្សធ្វើនោះទេ ។ សេចក្តីស្រឡាញ់មិនត្រឹមតែជាមនោសញ្ចេតនា ដែលយើងមានចំពោះមនុស្សណាម្នាក់ប៉ុណ្ណោះទេ គឺជាការសំរេចចិត្តប្រតិបត្តិតាមព្រះហឫទ័យព្រះជាម្ចាស់ដែលថា÷ « ត្រូវស្រឡាញ់អ្នកដទៃ អោយដូចជាស្រឡាញ់ខ្លួនឯង » ផងដែរ ។

តើយើងអាចមានសេចក្តីស្រឡាញ់របៀបនេះ ចំពោះអ្នកដទៃដោយរបៀបណា ? ព្រះយេស៊ូបង្រៀនពីរបៀបដែលនាំឱ្យអាចស្រឡាញ់អ្នកដទៃអោយដូចខ្លួនយើងបាន ។

កិច្ចការដែលត្រូវអនុវត្ត

- អធិស្ឋានសំរាប់សមាជិក ដើម្បីអោយពួកគេចាក់ឫសយ៉ាងមាំមួន ក្នុងសេចក្តីស្រឡាញ់ (អេភេសូ ៣:១៧) ។
- បង្រៀនសមាជិកក្រុមជំនុំអោយចេះស្រឡាញ់ព្រះជាម្ចាស់ និង ស្រឡាញ់គ្នាទៅវិញទៅមក និង ស្រឡាញ់អ្នកក្រៅពីក្រុមជំនុំដែរ ដោយការប្រព្រឹត្តអំពើល្អ (សូមធ្វើតាម ១ កូរិនថូស ជំពូក ១៣) ។
- ទន្ទេញ រ៉ូម ១២:១០ ។
- បើសិនជាមានសមាជិកខ្លះមិនចុះសម្រុងគ្នា ត្រូវទូន្មានពួកគេអោយត្រូវគ្នា និង ចេះស្រឡាញ់គ្នាទៅវិញទៅមក ។
- តើមានអ្នកជំនួយដែលមានបញ្ហា ឬ ធ្លាក់ទឹកចិត្តដែរឬទេ ? ។

  បើសិនជាមាន ត្រូវចំណាយពេលជាមួយពួកគេ ដើម្បីកសាងសេចក្តីស្រឡាញ់ និង លើកទឹកចិត្ត ហើយគាំទ្រគ្នាទៅវិញទៅមក ដូចដែលសាវ័កប៉ូលបានធ្វើជាមួយលោកធីម៉ូថេ ដែលជាសិស្សរបស់គាត់ដែរ ។ ព្រះរាជ្យរបស់ព្រះជាម្ចាស់នឹងរីកសាយ ដោយសារសេចក្តីស្រឡាញ់រវាងអ្នកដឹកនាំ និង អ្នកជំនួយដូចនេះ ។

«ការស្រឡាញ់មនុស្សឯទៀត អោយបានដូចស្រឡាញ់ខ្លួនឯង» មានន័យថា យើងត្រូវស្វែងរកផលប្រយោជន៍ខ្ពស់បំផុត សំរាប់មនុស្សឯទៀត ទោះជាលំបាកយ៉ាងណាក៏ដោយ ដូចជាយើងស្វែងរកផលប្រយោជន៍ខ្ពស់បំផុតសំរាប់ខ្លួនឯងដែរ ។

យើងមិននិយាយអាក្រក់ពីខ្លួនឯង មិនធ្វើអោយខ្លួនឯងឈឺចាប់ ឬ មិនបញ្ឆោតខ្លួនឯងយ៉ាងណា យើងក៏មិនត្រូវនិយាយអាក្រក់ពីអ្នកដទៃ មិនធ្វើអោយអ្នកដទៃឈឺចាប់ ឬ មិនកេងបន្លំ និង មិនភរអ្នកដទៃយ៉ាងនោះដែរ ។ យើងត្រូវមានចិត្តសប្បុរសចំពោះអ្នកដទៃ ហើយជួយពួកគេ និង លើកទឹកចិត្តពួកគេវិញ ។ អ្នកត្រូវមានគំនិតជាប់ជានិច្ចថា ត្រូវប្រព្រឹត្តជាមួយអ្នកដទៃ ដូចដែលអ្នកចង់អោយអ្នកដទៃប្រព្រឹត្តជាមួយអ្នកដែរ ។

ប្រភពនៃសេចក្តីស្រឡាញ់

សេចក្តីស្រឡាញ់ពិតប្រាកដ កើតមានដោយសារព្រះយេស៊ូគង់ក្នុងចិត្តយើង ។ សេចក្តីស្រឡាញ់ជាផលផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធ (រ៉ូម ៥:៥, កាឡាទី ៥:២២) ។ ហេតុនេះហើយបានជាអ្នកដែលមិនមែនជាគ្រីស្តជន មិនអាចមានសេចក្តីស្រឡាញ់ចំពោះខ្មាំងសត្រូវខ្លួនទេ ។

សូមរិះរករបៀបណាខ្លះ ដែលក្រុមជំនុំអ្នកអាចធ្វើ ដើម្បីលើកទឹកចិត្តសមាជិកក្រុមជំនុំ ឱ្យមានសេចក្តីស្រឡាញ់កាន់តែខ្លាំងឡើងៗ ។ ជួនកាល បើសិនជាកើតមានបញ្ហារវាងសមាជិក ការនាំអោយពួកគេធ្វើ«កិច្ចសន្យាព្រមព្រៀងសំរុះសំរួលគ្នា» អាចនាំអោយមានលទ្ធផលល្អ ។ សមាជិកទាំងអស់សន្យាថា នឹងអត់ទោស និង បំភ្លេចការខុសឆ្គងដែលមានកន្លងមក ហើយសន្យាថា នឹងឈប់ឈ្លោះប្រកែកគ្នា និង ទិតៀនគ្នាទៀត ។ ពួកគេប្តេជ្ញាថា នឹងមានសេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក ។ ក្រោយពីបានធ្វើកិច្ចព្រមព្រៀងនេះហើយ សមាជិកដែលនៅតែបន្តបំបែកបំបាក់ក្រុមជំនុំ នឹងត្រូវទទួលការអប់រំប្រៀនប្រដៅ ។

កម្មវិធីប្រកបគ្នាក៏សំខាន់ដែរ ដូចជាដំណើរកំសាន្ត ការហូបបាយជុំគ្នា ។ល។ ដើម្បីអោយសមាជិកស្គាល់គ្នា និង ជួយគ្នាទៅវិញទៅមក ។

សូមចាប់ផ្តើមអធិស្ឋានសំរាប់អ្នកនោះ ។

បើអ្នកជាឪពុកម្តាយ អ្នកត្រូវរិះរកវរបៀបជាក់ស្តែង ដើម្បីបង្ហាញសេចក្តីស្រឡាញ់កាន់តែខ្លាំងចំពោះកូនៗ ។ សូមសរសេរពីរបៀបនោះ :

_____

_____

_____

បើអ្នកជាប្តី ឬ ប្រពន្ធ អ្នកត្រូវរិះរកវរបៀបជាក់ស្តែង ដើម្បីបង្ហាញសេចក្តីស្រឡាញ់កាន់តែខ្លាំងចំពោះប្រពន្ធ ឬ ប្តីរបស់អ្នក ។ សូមសរសេរពីរបៀបនោះ :

_____

_____

_____

_____

_____

សេចក្តីស្រឡាញ់ជាភស្តុតាងបង្ហាញថា :

☐ ព្រះវិញ្ញាណដ៏វិសុទ្ធគង់ក្នុងយើង ។

☐ យើងកាន់សាសនា ។

សេចក្តីស្រឡាញ់ដ៏ពិតរបស់គ្រីស្តជន ជាលទ្ធផលនៃការដែលព្រលឹងវិញ្ញាណរបស់យើងបានរួមជាមួយព្រះយេស៊ូ ដោយសារព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ។



តើយើងអាចបង្ខំមនុស្សអោយស្រឡាញ់ដែរឬទេ ?

☐ អាច ។

☐ មិនអាចទេ ។

តើសេចក្តីស្រឡាញ់របស់គ្រីស្តជនមានប្រភពមកពីណា ? ។

_____

_____

សូមរកមើលចំលើយនៅក្នុងគម្ពីរ កាឡាទី ៥:២២ ។ យើងមានសេចក្តីស្រឡាញ់កាន់តែខ្លាំង ដោយសារការអធិស្ឋាន ការលើកទឹកចិត្តគ្នាទៅវិញទៅមក និង ការអានព្រះបន្ទូលព្រះជាម្ចាស់ ។

លិខិតទី ១ ជំពូក ១៣ ដែលលោកប៉ូលផ្ញើទៅកាន់គ្រីស្តបរិស័ទនៅទីក្រុងកូរិនថូស បង្រៀនយើងអំពីផលផ្លែរបស់ព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ក្នុងយើង ។ យើងនឹងសិក្សាជំពូកដែលនិយាយពីសេចក្តីស្រឡាញ់នេះ ដោយពិស្តារ ។



តើជំពូកណាមួយរបស់ព្រះគម្ពីរ ដែលពន្យល់ថា អំណោយទានខាងព្រលឹងវិញ្ញាណដែលគ្មានសេចក្តីស្រឡាញ់ គ្មានប្រយោជន៍អ្វីទាំងអស់ ?

☐ យេរេមី ជំពូក ៥២ ។

☐ ១ កូរិនថូស ជំពូក ១៣ ។

☐ វិវរណៈ ជំពូក ១៣ ។

១ កូរិនថូស ជំពូក ១២ និយាយពីសារៈសំខាន់នៃអំណោយទានផ្សេងៗ សំរាប់បំពេញមុខងារបំរើ ។ ១ កូរិនថូស ជំពូក ១៣ ពន្យល់ថា អំណោយទានទាំងអស់ ដែលគ្មានសេចក្តីស្រឡាញ់ គ្មានប្រយោជន៍ទាល់តែសោះ ។

សូមគិតពីអ្នកជិតខាងម្នាក់ ឬ សាច់ញាតិម្នាក់ ឬ មិត្តភក្តិម្នាក់ ដែលអ្នកមានទំនាក់ទំនងមិនល្អជាមួយ (ទោះជាដោយសារកំហុសរបស់អ្នកនោះ ឬ កំហុសរបស់អ្នកផ្ទាល់ក៏ដោយ) ហើយសូមនឹកឃើញពីសេចក្តីត្រូវការណាមួយរបស់អ្នកនោះ ដែលអ្នកអាចបំពេញបាន ដើម្បីជួយគាត់ ។ តើអ្នកនោះមានបញ្ហា ឬ សេចក្តីត្រូវការណាខ្លះ ដែលអ្នកអាចជួយដោះស្រាយគាត់បាន ? ។_____

_____

© Project WorldReach © SEAN

១ ពេត្រុស ១:២២

១ យ៉ូហាន ៤:៧-២១

១ យ៉ូហាន ៣:១០-១៨

១ កូរិនថូស ជំពូក ១៣

ទុតិយកថា ៦:៤-៦

តើព្រះយេស៊ូ និង សាវ័ករបស់ព្រះអង្គចាត់ទុកថា សេចក្តីស្រឡាញ់សំខាន់ដល់កំរិតណា ?

☐ មិនសូវសំខាន់ ។

☐ សំខាន់ ។

☐ សំខាន់ខ្លាំងណាស់ ។

ចុះអ្នកវិញ ? តើអ្នកចាត់ទុកសេចក្តីស្រឡាញ់សំខាន់យ៉ាងណាចំពោះជីវិត ការងារ ក្រុមគ្រួសារ អ្នកជិតខាង និង កិច្ចការបំរើរបស់អ្នក ?

☐ មិនសូវសំខាន់ ។

☐ សំខាន់ខ្លះដែរ ។

☐ ដោយមានព្រះជាម្ចាស់ជួយ មានសារៈសំខាន់ណាស់ ។

១ កូរិនថូស ១៣:១-២

"ទោះបីខ្ញុំចេះនិយាយភាសារបស់មនុស្សលោក និង ភាសារបស់ទេវតាក្តី បើសិនជាខ្ញុំគ្មានសេចក្តីស្រឡាញ់ទេ ខ្ញុំប្រៀបដូចជាសំឡេងគង ដែលលាន់ឮឡើង ឬ ដូចជាស្គរដែលឮរំពងឡើងតែប៉ុណ្ណោះ ។ ទោះបីខ្ញុំទទួលព្រះអំណោយទានខាងថ្លែងព្រះបន្ទូល និង ស្គាល់គំរោងការដ៏លាក់កំបាំងទាំងអស់ ព្រមទាំងមានចំណេះគ្រប់យ៉ាង ហើយទោះបីខ្ញុំមានជំនឿមាំ រហូតដល់ធ្វើអោយភ្នំរើពីកន្លែងមួយទៅកន្លែងមួយទៀតបានក្តី តែបើសិនជាខ្ញុំគ្មានសេចក្តីស្រឡាញ់ទេនោះ ខ្ញុំជាមនុស្សឥតបានការអ្វីទាំងអស់" ។

អំណោយទានខាងព្រលឹងវិញ្ញាណមានប្រយោជន៍ណាស់ បើសិនជាយើងយកមកអនុវត្ត ដោយសេចក្តីស្រឡាញ់ ។ អ្នកខ្លះមិនបានប្រើអំណោយទានខាងព្រលឹងវិញ្ញាណរបស់ខ្លួន ដើម្បីថ្វាយសិរីរុងរឿងទៅព្រះជាម្ចាស់ និង កសាងក្រុមជំនុំឡើងទេ តែដើម្បីអោយបានសប្បាយចិត្តខ្លួនឯង ឬក៏ឱ្យគេចាប់អារម្មណ៍លើខ្លួនទៅវិញ ។



១ កូរិនថូស ១៣:១៣

"ឥឡូវនេះ មានសេចក្តីបីយ៉ាង គឺ ជំនឿ សេចក្តីសង្ឃឹម សេចក្តីស្រឡាញ់ ។ ប៉ុន្តែ សេចក្តីស្រឡាញ់វិសេសជាងគេបំផុត" ។

ខព្រះគម្ពីរចុងក្រោយរបស់ជំពូកនេះ និយាយពីសារៈសំខាន់នៃសេចក្តីស្រឡាញ់ ។ សេចក្តីស្រឡាញ់រហូតហ៊ានធ្វើពលិកម្ម មិនសាបសូន្យទេ ។ សេចក្តីស្រឡាញ់ដូចនេះ ធ្វើអោយអំណោយទានខាងព្រលឹងវិញ្ញាណមានប្រយោជន៍ ។ សេចក្តីស្រឡាញ់ក៏វិសេសជាងជំនឿ និង សេចក្តីសង្ឃឹមដែរ ។ សម្ពន្ធមេត្រីថ្មីទាំងមូលរៀបរាប់ពីសារៈសំខាន់នៃសេចក្តីស្រឡាញ់ ។

វគ្គព្រះគម្ពីរដែលបង្រៀនពីសេចក្តីស្រឡាញ់ :

ម៉ាថាយ ៥:៣៨-៤៨	លូកា ១០:២៥-៣៧
រ៉ូម ១២:៩-២១	អេភេសូ ៣:១៤-២១
រ៉ូម ១៣:៨-១០	អេភេសូ ៥:២៥-៣៣
កូឡូស ៣:១២-១៥	១ ធីម៉ូថេ ១:៥
ភីលេម៉ូន ១:៤-២០	ហេប្រឺ ១៣:១-៥

តើអ្នកអាចធ្វើការងារស៊ីសង្វាក់គ្នាជាមួយអ្នកជឿឯទៀត នៅក្នុងស្ថានភាពផ្ទាល់ខ្លួន ឬ ក្នុងស្ថានភាពក្រុមជំនុំ ដោយរបៀបណា ? ។

_____

_____

_____

ភស្តុតាងជាក់ស្តែងនៃសេចក្តីស្រឡាញ់ពិត គឺ :

☐ ពាក្យសំដីល្អៗ ។

☐ ការប្រព្រឹត្តល្អ ។

☐ ទឹកចិត្តស្រឡាញ់ជ្រាលជ្រៅ ។

សូមរកចំលើយនៅក្នុង ១ យ៉ូហាន ៣:១៨ ។



បើយើងបំពេញមុខងារបំរើតាមអំណោយទាន តែគ្មានសេចក្តីស្រឡាញ់ កិច្ចការដែលយើងធ្វើ និង អំណោយទានដែលយើងមាននោះគ្មានតំលៃអ្វីឡើយ ។ សូម្បីតែពេលយើងអធិប្បាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ បើសិនជាយើងអធិប្បាយ ដោយគ្មានសេចក្តីស្រឡាញ់ទេនោះ :

☐ មានតំលៃណាស់សំរាប់ព្រះជាម្ចាស់ ។

☐ គ្មានប្រយោជន៍ទាល់តែសោះ ។

បើសិនជាយើងយកអំណោយទានមកអនុវត្តសំរាប់ផលប្រយោជន៍យើងផ្ទាល់ យើងលើកតម្កើងខ្លួនយើង មិនមែនថ្វាយបង្គំព្រះជាម្ចាស់ទេ ។ ទុតិយកថា ៦:៤-៦ ចែងថា «*អ៊ីស្រាអែលអើយ ចូរស្តាប់ ! មានតែព្រះអម្ចាស់ជាព្រះរបស់យើងមួយព្រះអង្គគត់ដែលពិតជាព្រះអម្ចាស់ ។ អ្នកត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះ-របស់អ្នក អោយអស់ពីចិត្តគំនិត អស់ពីស្មារតី និង អស់ពីកម្លាំងកាយ* » ។

មានតែការងារ ឬ ពលិកម្មដែលយើងធ្វើ ដោយសេចក្តីស្រឡាញ់ថ្វាយព្រះគ្រីស្តប៉ុណ្ណោះ ដែលមានប្រយោជន៍ ។

១ កូរិនថូស ១៣:៣

"ទោះបីខ្ញុំយកទ្រព្យសម្បត្តិរបស់ខ្ញុំទាំងប៉ុន្មានទៅចែកទានក្តី ទោះបីខ្ញុំសុខចិត្តអោយគេយកឫបកាយខ្ញុំទៅដុតទាំងរស់ក្តី តែបើសិនជាខ្ញុំគ្មានសេចក្តីស្រឡាញ់ទេនោះ ក៏គ្មានប្រយោជន៍អ្វីដល់ខ្ញុំដែរ" ។



នៅទីបញ្ចប់ តើគុណសម្បត្តិណាមួយរបស់ពួកគ្រីស្តជន ដែលមានមានតម្លៃជាងគេ នៅចំពោះព្រះភក្ត្រព្រះជាម្ចាស់ ? ។ _____

តើការប្រព្រឹត្តណាមួយ ដែលបង្ហាញសេចក្តីស្រឡាញ់រវាងនិកាយផ្សេងៗ ខ្លាំងជាងគេ ?

☐ មានជំណើរការ «ឯករាជ្យតែឯង» ជានិច្ច ។

☐ សហការជាមួយក្រុមជំនុំឯទៀត ។

តើការប្រព្រឹត្តណាមួយ ដែលបង្ហាញពីភាពចាស់ទុំខាងព្រលឹងវិញ្ញាណ ខ្លាំងជាងគេ ?

☐ បង្ហាញសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ ដើម្បីអោយពួកគេគាំទ្រខ្ញុំ ។

☐ បង្ហាញសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ ទោះជាពួកគេមិនគាំទ្រខ្ញុំក៏ដោយ ។

ស្មារតីនៅដាច់ពីគេ មិនមែនមកពីព្រះជាម្ចាស់ទេ ។ ពីព្រោះសេចក្តីស្រឡាញ់ជីកនាំយើង អោយធ្វើការងារស៊ីសង្វាក់គ្នាជាមួយអ្នកជឿឯទៀត ។

១ កូរិនថូស ១៣:១១-១២

"កាលពីក្មេង ខ្ញុំនិយាយស្តីដូចកូនក្មេង ខ្ញុំមានគំនិតដូចជាកូនក្មេង ហើយខ្ញុំរិះគិតដូចកូនក្មេងដែរ ។ លុះខ្ញុំពេញវ័យ ខ្ញុំបានចោះបង់អ្វីៗទាំងអស់ដែលជាលក្ខណៈរបស់កូនក្មេងចោល ។ សព្វថ្ងៃនេះ យើងស្គាល់ព្រះជាម្ចាស់មិនច្បាស់ទេ គឺស្គាល់ព្រាលៗដូចជាមើលក្នុងកញ្ចក់ នៅពេលខាងមុខ ទើបយើងឃើញព្រះអង្គទល់មុខគ្នា ។ សព្វថ្ងៃ ខ្ញុំស្គាល់ព្រះអង្គបានត្រឹមតែមួយផ្នែកប៉ុណ្ណោះ ពេលខាងមុខទើបខ្ញុំស្គាល់ព្រះអង្គច្បាស់ ដូចព្រះអង្គស្គាល់ខ្ញុំយ៉ាងច្បាស់ដែរ" ។

នៅក្នុងជីវិតយើងជាគ្រីស្តជន យើងត្រូវតែរីកចំរើនឡើងជាចាស់ទុំខាងព្រលឹងវិញ្ញាណ ដោយកែប្រែបន្តិចម្តងៗ ទៅតាមលក្ខណៈរបស់ព្រះយេស៊ូគ្រីស្ត (២ កូរិនថូស ៣:១៨) ។ នៅពេលដែលយើងមានជំនឿកាន់តែរឹងមាំ នោះយើងកាន់តែមានលក្ខណៈសម្បត្តិដូចព្រះគ្រីស្ត និង កាន់តែមានអំណោយទានក្នុងជីវិតរបស់យើង ។ ឧទាហរណ៍ ជំនឿរឹងមាំនាំអោយយើងមានកិរិយាល្អ ស្គាល់ព្រះអង្គចេះទប់ចិត្ត ព្យាយាមតស៊ូ គោរពប្រណិប័តន៍ព្រះជាម្ចាស់ មានភាតរភាព និង មានសេចក្តីស្រឡាញ់បន្ថែមទៀត (២ ពេត្រុស ១:៥-៧) ។

១ កូរិនថូស ១៣:៤ (ក)

"អ្នកមានចិត្តស្រឡាញ់ តែងតែអត់ធ្មត់..." ។

តើការអត់ធ្មត់មានន័យដូចម្តេចចំពោះអ្នក ? ។ _____

ការអត់ធ្មត់ជាការទ្រាំទ្រការឈឺចាប់ និង ទុក្ខលំបាកដោយគ្មានត្អូញត្អែរ ។ ទុក្ខលំបាក និង ការធ្លាក់ទឹកចិត្តរបស់យើងភាគច្រើនកើតមានដោយសារមនុស្សឯទៀត ។ ដូចនេះ សេចក្តីស្រឡាញ់ជាការអត់ធ្មត់ចំពោះមនុស្ស ដែលធ្វើខុសមកលើយើង ។

ព្រះយេស៊ូមានព្រះហឫទ័យអត់ធ្មត់ចំពោះមនុស្សណាស់ ។ សូម្បីតែមនុស្សពោលពាក្យប្រមាថព្រះអង្គ ធ្វើទុក្ខទោសព្រះអង្គ ក៏ព្រះអង្គមិនបានតបតនឹងគេ ដើម្បីសងសឹកវិញដែរ ។ តែព្រះអង្គណែនាំពួកគេ ដោយសេចក្តីស្រឡាញ់ ហើយអត់ទោសអោយពួកគេថែមទៀតផង ។ សូមនឹកចាំពីព្រះបន្ទូលរបស់ព្រះយេស៊ូនៅលើឈើឆ្កាង «ព្រះបិតាអើយ សូមអត់ទោសដល់ពួកគេផង ដ្បិតពួកគេមិនដឹងថា ពួកគេកំពុងតែធ្វើអ្វីទេ» ។ នៅក្នុងគម្ពីរយ៉ូហាន ១៣:៣៤ ព្រះយេស៊ូបង្គាប់យើងថា ត្រូវមានសេចក្តីស្រឡាញ់ដូចព្រះអង្គស្រឡាញ់យើងដែរ ។

តើខ្ញុំគួរធ្វើដូចម្តេច បើអ្នកជិតខាងខ្ញុំលួចខ្ញុំ ? តើខ្ញុំគួរធ្វើដូចម្តេច បើមានសមាជិកក្រុមជំនុំម្នាក់ ចេះតែពោលពាក្យប្រមាថខ្ញុំឥតឈប់ឈរយ៉ាងនេះ ? ត្រូវខិតខំអត់ធ្មត់ ហើយអត់ទោសឱ្យគេ ។



យើងបង្ហាញថា យើងចេះអត់ធ្មត់ នៅពេលដែលយើងអត់ទោសអោយមនុស្សឯទៀត គឺយើងអត់ទោសដោយមានសេចក្តីស្រឡាញ់ជំនឿ និង ដោយសារយើងចេះស្តាប់តាមបង្គាប់របស់ព្រះជាម្ចាស់

១ កូរិនថូស ១៣:៨-១០

"សេចក្តីស្រឡាញ់មិនសាបសូន្យសោះឡើយ តែការថ្លែងព្រះ-បន្ទូលមុខជាត្រូវអស់ខ្លឹមសារ ការនិយាយភាសាចំឡែកអស្ចារ្យ នឹងត្រូវចប់ រីឯចំណេះក៏នឹងអស់ខ្លឹមសារទៅដែរ ។ សព្វថ្ងៃនេះ យើងចេះដឹងត្រឹមតែមួយផ្នែកប៉ុណ្ណោះ ហើយយើងក៏ថ្លែងព្រះ-បន្ទូលបានត្រឹមតែមួយផ្នែកប៉ុណ្ណោះដែរ ។ លុះដល់ពេលយើងដឹងសព្វគ្រប់ហើយ អ្វីៗដែលយើងស្គាល់តែមួយផ្នែកនឹងអស់ខ្លឹមសារ" ។

យោងទៅតាមខទាំងនេះ តើអ្វីដែលមិនចេះសាបសូន្យ ?

☐ ការនិយាយជាភាសាចំឡែកអស្ចារ្យ ។

☐ ការថ្លែងព្រះបន្ទូល ។

☐ សេចក្តីស្រឡាញ់ ។

កំណត់ចំណាំ : សូមពិនិត្យមើលចំលើយរបស់អ្នក នៅក្នុង ខ ៨-១០ ។

សូមអាន ១ កូរិនថូស ១៣:៧ ម្តងទៀត ហើយគិតពីសត្រូវរបស់អ្នក :

«អ្នកមានចិត្តស្រឡាញ់ អត់ឱនអោយទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំងអស់ ហើយទ្រាំទ្រទាំងអស់ » ។

តើអ្នកមានសត្រូវ ដែលអ្នកត្រូវផ្សះផ្សាជានាជាមួយនឹងគេដែរឬទេ ? ។

(ម៉ាកុស ១១:២៥-២៦) ។ យើងមិនគួររង់ចាំរហូតដល់យើងមានអារម្មណ៍ល្អចំពោះមនុស្ស ដែលធ្វើខុសមកលើយើងទេ ។ តែយើងត្រូវទូលសូមអោយព្រះជាម្ចាស់ជួយយើង ឱ្យអាចអត់ទោសដល់គេ មុនដែលការខកចិត្តរបស់យើងក្លាយជាគំនុំ ។ សេចក្តីស្រឡាញ់ធ្វើឱ្យយើងចេះអត់ធ្មត់ជាមួយមនុស្សឯទៀត និង ជាមួយអស់អ្នកដែលធ្វើអោយយើងអន់ចិត្ត ។

១ កូរិនថូស ១៣:៤ (ខ)

"អ្នកមានចិត្តស្រឡាញ់...ជួយធុរៈគេ" ។



មានចិត្តល្អជួយធុរៈគេ គឺធ្វើអំពើល្អ ដោយសារមានសេចក្តីស្រឡាញ់ ។ ឧទាហរណ៍ តើអ្នកដាក់ដង្វាយដប់ភាគរយ ដោយចិត្តស្រឡាញ់ដែរឬទេ ?

☐ ដាក់ដោយចិត្តស្រឡាញ់ ។

☐ អត់ទេ ។

១ កូរិនថូស ១៣:៤ (ត)

"អ្នកមានចិត្តស្រឡាញ់...មិនចេះឈ្នានីសគេទេ..." ។



ព្រះយេស៊ូមានព្រះបន្ទូលថា÷ «ចូរស្រឡាញ់ខ្មាំងសត្រូវរបស់អ្នករាល់គ្នា ព្រមទាំងទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរឱ្យអស់អ្នកដែលបៀតបៀនអ្នករាល់គ្នាផង ។ ធ្វើដូច្នេះ អ្នករាល់គ្នានឹងបានទៅជាបុត្រធីតារបស់ព្រះបិតា ដែលគង់នៅស្ថានបរមសុខ ដ្បិតព្រះអង្គប្រទានអោយព្រះអាទិត្យរបស់ព្រះអង្គ រះបំភ្លឺទាំងមនុស្សអាក្រក់ ទាំងមនុស្សល្អ ហើយទ្រង់ប្រទានទឹកភ្លៀងឱ្យ ទាំងមនុស្សសុចរិត ទាំងមនុស្សទុច្ចរិតផងដែរ ។ ប្រសិនបើអ្នករាល់គ្នាស្រឡាញ់តែអស់អ្នកដែលស្រឡាញ់អ្នករាល់គ្នា តើនឹងទទួលរង្វាន់អ្វី ? សូម្បីតែអ្នកទារពន្ធក៏ចេះស្រឡាញ់គ្នាគេដែរ ។ បើអ្នករាល់គ្នារាប់រកតែបងប្អូនរបស់ខ្លួនប៉ុណ្ណោះ តើមានអ្វីអស្ចារ្យ ? សូម្បីតែសាសន៍ដទៃ ក៏ប្រព្រឹត្តដូច្នោះដែរ ។ ព្រះបិតារបស់អ្នករាល់គ្នា ដែលគង់នៅស្ថានបរមសុខ ទ្រង់គ្រប់លក្ខណ៍យ៉ាងណា សុំអោយអ្នករាល់គ្នាបានគ្រប់លក្ខណ៍យ៉ាងនោះដែរ » ។

(ម៉ាថាយ ៥:៤៤-៤៨)

តើអ្នកធ្វើតាមគំរូរបស់អ្នកស្រុកសាម៉ារី ដើម្បីជួយបំពេញសេចក្តី-ត្រូវការរបស់សង្កាត់អ្នក ដែលអ្នកបានរៀបរាប់នៅទំព័រ ទី ៣៩ ដោយរបៀបណា ? ។ _____

_____

យើងបាននិយាយអំពីមនុស្សមានសេចក្តីស្រឡាញ់ ដែលចេះទ្រាំទ្រទាំងអស់នៅក្នុងក្រុមជំនុំ នៅក្នុងក្រុមគ្រួសារ និង ចំពោះមនុស្សឯទៀតហើយ ។ ឥឡូវនេះ យើងចូលដល់ផ្នែក ដែលពិបាកបំផុតវិញម្តង គឺ :

អ្នកមានចិត្តស្រឡាញ់ ចេះទ្រាំទ្រទាំងអស់ ចំពោះខ្មាំងសត្រូវខ្លួន

ព្រះយេស៊ូបង្រៀនថា សេចក្តីស្រឡាញ់ ជាកូនសោសំរាប់ធ្វើឱ្យមនុស្សបានគ្រប់លក្ខណ៍ ។



អាចមានសមាជិកដែលមានចិត្តច្រណែន ចង់ធ្វើជាគ្រូគង្វាល ឬអ្នកដឹកនាំ ។ អ្នកនោះបំបែកបំបាក់ក្រុមជំនុំ ។ អ្នកនោះខិតខំចង់ធ្វើជាអ្នកដឹកនាំ មិនមែនដោយសារមានចិត្តស្រឡាញ់ចំពោះមនុស្សទេ តែដើម្បីប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ ។

មនុស្សដូចនេះ មាន :

☐ សេចក្តីស្រឡាញ់ពិត ។

☐ មហិច្ឆិតាផ្ទាល់ខ្លួន ។

១ កូរិនថូស ១៣:៤ (ឃ)

"អ្នកមានចិត្តស្រឡាញ់ មិនវាយឫកខ្ពស់ និង មិនអួតបំពោងឡើយ" ។



តើអាកប្បកិរិយាអួតបំប៉ោងខ្លួនដូចនេះ មានឥទ្ធិពលដូចម្តេចទៅលើសមាជិកឯទៀត ?

☐ លើកទឹកចិត្តសមាជិកឯទៀត ។

☐ ធ្វើអោយសមាជិកឯទៀតធ្លាក់ទឹកចិត្ត ។



យើងត្រូវស្រឡាញ់ព្រះជាម្ចាស់អោយអស់ពីចិត្ត អស់ពីព្រលឹង អស់ពីកម្លាំង និង ត្រូវស្រឡាញ់មនុស្សឯទៀតអោយដូចខ្លួនឯង ។ ប៉ុន្តែ យោងទៅតាមប្រស្នានេះ តើយើងត្រូវធ្វើជាមនុស្សល្អពិតចំពោះអ្នកដទៃ ដោយរបៀបណា ?

☐ ដោយរស់នៅក្នុងសង្កាត់ជាមួយគ្នា ។

☐ ដោយបង្ហាញទឹកចិត្តមេត្តាករុណាចំពោះមនុស្សខ្វះខាត ។

ត្រូវមានសេចក្តីស្រឡាញ់ចំពោះមនុស្សណា ដែលត្រូវការជំនួយ ទោះជាអ្នកនោះជាមិត្ត ឬ ជាសត្រូវក៏ដោយ ។ តើនៅក្នុងសង្កាត់របស់អ្នក មានសេចក្តីត្រូវការអ្វីខ្លះ ដែលក្រុមជំនុំរបស់អ្នកអាចជួយបាន ? ។

នៅក្នុងរឿងរបស់ព្រះគម្ពីរ លូការ ១០:២៥-៣៧ នេះ តើអ្នកណាដែលប្រព្រឹត្ត ដោយសេចក្តីស្រឡាញ់ ?

☐ បូជាចារ្យ ។

☐ បុរសលេវី ។

☐ អ្នកស្រុកសាម៉ារី ។

អ្នកមានចិត្តស្រឡាញ់ ចេះទ្រាំទ្រទាំងអស់ ចំពោះមនុស្សឯទៀត

អានរឿងអំពីអ្នកស្រុកសាម៉ារីម្នាក់ដែលមានចិត្តសប្បុរស នៅក្នុង លូកា ១០:២៥-៣៧ ។

យោងទៅតាមជំណើររឿងនេះ តើយើងត្រូវស្រឡាញ់ព្រះជាម្ចាស់យ៉ាងណា ?

☐ អោយអស់ពីចិត្ត អស់ពីព្រលឹង អស់ពីកម្លាំង ។

☐ ដូចខ្លួនឯង ។

តើយើងត្រូវស្រឡាញ់មនុស្សឯទៀតយ៉ាងណា ?

☐ អោយអស់ពីចិត្ត អស់ពីព្រលឹង អស់ពីកម្លាំង ។

☐ ដូចខ្លួនឯង ។

ការវាយឫកខ្ពស់ ធ្វើអោយសមាជិកឯទៀតធ្លាក់ទឹកចិត្ត ហើយបណ្តាលអោយការងាររបស់ព្រះជាម្ចាស់មិនរីកចំរើនទៅមុខ ។



មនុស្សវាយឫកខ្ពស់ តែងតែប្រៀបធៀបខ្លួនឯង ជាមួយអ្នកផ្សេងទៀត ដែលមើលទៅដូចជាទន់ខ្សោយជាងខ្លួន ។ ប៉ុន្តែ គ្រីស្តជនត្រូវប្រៀបធៀបខ្លួនជាមួយ :

☐ មនុស្សឯទៀតដែលគ្រាន់បើជាងខ្លួន ។

☐ ព្រះគ្រីស្ត ។

សូមរកចំលើយនៅក្នុង ២ កូរិនថូស ១០:១២-១៨ ។

នៅពេលដែលយើងភ្លេចខ្លួន មារសាតាំងតែងតែល្បួងយើងអោយមានអំនួត និង វាយឫកខ្ពស់ ។



គ្រីស្តជនដែលមានសេចក្តីស្រឡាញ់ តែងតែចៀសវាងមិនគ្នាញ្ញែរនៅក្នុងផ្ទះខ្លួនទេ ពីព្រោះគាត់ចេះស៊ូទ្រាំ ។ សេចក្តីប្រច័ណ្ឌនឹងរលាយបាត់អស់ ដោយសារការចេះទុកចិត្តគ្នា និង ការចេះអត់ឱនអោយគ្នាទៅវិញទៅមក ហើយកំហឹង និង ការឈ្លោះប្រកែកគ្នាក៏ឈប់កើតមានដែរ ព្រោះអ្នកមានសេចក្តីស្រឡាញ់ ចេះស៊ូទ្រាំគ្រប់យ៉ាង ។



លំនៅដ្ឋាន ដែលមានគ្រីស្តជនពោរពេញដោយសេចក្តីស្រឡាញ់ ជាអ្នកគ្រប់គ្រង ជាផ្នែកតូចមួយនៃស្ថានបរមសុខនៅលើផែនដី ។



១ កូរិនថូស ១៣:៥ (ក)

“អ្នកមានចិត្តស្រឡាញ់...មិនប្រព្រឹត្តអំពើថោកទាប” ។

អំពើធឹតក្បត់ បន្ទាបបន្ថោកសេចក្តីស្រឡាញ់រវាងស្វាមី និង ភរិយា ។ ការមិនស្តាប់បង្គាប់ បន្ទាបបន្ថោកសេចក្តីស្រឡាញ់ រវាងកូន និង មាតាបិតា ។ ការបបួលមិត្តភក្តិអោយធ្វើអំពើបាប បន្ទាបបន្ថោកមេត្រីភាពរវាងមិត្តភក្តិ ។



១ កូរិនថូស ១៣:៥ (ខ)

"អ្នកមានចិត្តស្រឡាញ់.....មិនស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន" ។





អ្នកមានចិត្តស្រឡាញ់ ចេះទ្រាំទ្រទាំងអស់ក្នុងក្រុមគ្រួសារ

សូមគិតគូរពីក្រុមគ្រួសាររបស់អ្នក នៅពេលដែលអ្នកអានខគម្ពីរនេះឡើងវិញ :

«អ្នកមានចិត្តស្រឡាញ់ អត់ឱនឱ្យទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំងអស់ ហើយទ្រាំទ្រទាំងអស់» ។

(១ កូរិនថូស ១៣:៧)



១ កូរិនថូស ៥:១០-១១ ហាមមិនអោយទាក់ទងជាមួយអ្នកដែលមានឈ្មោះថាជាគ្រីស្តបរិស័ទ តែបែរជាមានចិត្តលោភលន់ :



មារសាតាំងល្បួងយើងអោយមានចិត្តអាត្មានិយម ដើម្បីបំផ្លាញសេចក្តីស្រឡាញ់ ដែលមាននៅក្នុងចិត្តយើង ។



អ្នកមានសេចក្តីស្រឡាញ់តែងតែប្រែប្រួលក្នុងក្រុមជំនុំ

អ្នកមានសេចក្តីស្រឡាញ់ តែងតែខិតខំផ្សះផ្សាអ្នកឯទៀត ។ ប៉ុន្តែក្នុងករណីខ្លះ សមាជិកនៅតែធ្វើអោយក្រុមជំនុំបែកបាក់គ្នា ឬ លួច ឬ ប្រព្រឹត្តអំពើប្រាសចាកសីលធម៌ ឬ និយាយអាក្រក់ ឬ ប្រមឹកស្រា ។ បើសិនជាបានខិតខំផ្សះផ្សាបងប្អូនណាម្នាក់ ដែលបានប្រព្រឹត្តអំពើបាបដោយធ្ងៃគ្រប់ជំហាន យោងទៅតាម ម៉ាថាយ ១៨:១៥-២២ ហើយ (គឺបានដាស់តឿនអ្នកនោះស្ងាត់ៗតែពីរនាក់ រួចដាស់តឿនអ្នកនោះ ដោយមានសាក្សីពីរបីនាក់ ហើយដាស់តឿនអ្នកនោះ នៅចំពោះមុខក្រុមជំនុំ)ក៏ប៉ុន្តែសមាជិកនោះនៅតែប្រព្រឹត្តអំពើបាបទៀត យើងមិនត្រូវឱ្យគាត់មកចូលរួមជាមួយយើងទៀតឡើយ (រ៉ូម ១៦:១៧, ១ កូរិនថូស ៥:១១) ។

តើអ្នកបញ្ឈប់សមាជិកដែលមានកំហុសដូចនេះ មិនឱ្យមកចូលរួមក្នុងក្រុមជំនុំដែរឬទេ ? ។ _____

តើអ្នកអធិស្ឋានអោយគាត់ដែរឬទេ ? ។ _____

អ្នកមានសេចក្តីស្រឡាញ់តែងតែសង្ឃឹមជានិច្ច ។ ត្រូវទុកចិត្តថា អស់អ្នកដែលកែប្រែចិត្តគំនិត ហើយទទួលជឿព្រះយេស៊ូគ្រីស្ត អស់ពីចិត្តនោះ បានសង្គ្រោះហើយ ។ យើងត្រូវជួយអ្នកជឿថ្មី អោយអាចយល់ថា ពួកគេពិតជាបានសង្គ្រោះរហូតអស់កល្ប ក្នុងព្រះគ្រីស្ត ។ បើសិនជាយើងទុកអោយគេនៅតែសង្ស័យ ឆ្កែចចកស្រួលនឹងនាំពួកគេ « អោយខិតខំសង្គ្រោះខ្លួនឯង » ដោយខំធ្វើអំពើល្អ និង ដោយកំឡាំងគេផ្ទាល់ ឬក៏ឆ្កែចចកនាំឱ្យពួកគេចូលរួមជាមួយនិកាយខុសឆ្គងមិនខាន ។



មនុស្សអាត្មានិយម មិនចង់ចែកចាយជាមួយមនុស្សឯទៀតទេ ។ អ្នកដែលមានសេចក្តីស្រឡាញ់ធ្វើអំណោយ ដាក់ដង្វាយដោយចិត្តសប្បុរស ទាំងប្រាក់ ទាំងរបស់របរ ទាំងការងារ ។ អ្នកនោះចេះជួយអ្នកដទៃ ។ ឧទាហរណ៍ បុរសម្នាក់បង្រៀនអ្នកណាម្នាក់អោយចេះអានអក្សរ ។

តើអ្នកចង់ជួយអ្នកដទៃដូចនេះទេ ? ។_____

ជួយដោយរបៀបណា ? ។ _____

_____

_____

_____

_____

_____

_____

_____

_____

១ កូរិនថូស ១៣:៥ (គ)

"អ្នកមានចិត្តស្រឡាញ់...មិនមួម៉ៅ " ។



គ្រូគង្វាលដែលមានសេចក្តីស្រឡាញ់ ត្រូវ :

☐ គ្រប់គ្រងមនុស្ស ដោយសម្ពុត ។

☐ ដឹកនាំដោយចិត្តសុភាពរាបសា និង ស្លូតបូត ។

បើលោកគ្រូគង្វាលប្រើពាក្យធ្ងន់ៗ នោះសមាជិកនឹងធ្លាក់ទឹកចិត្ត ។ ឯសេចក្តីស្រឡាញ់ លើកទឹកចិត្ត និង បង្រួបបង្រួមសមាជិកទៅវិញទេ ។

គ្រូគង្វាលថែរក្សាអ្នកជឿថ្មី ដោយមានសេចក្តីសង្ឃឹមមាំមួន ។





១ កូរិនថូស ១៣:៥ (ឃ)

***"អ្នកមានចិត្តស្រឡាញ់...មិនចងគំនុំ"* ។**



តើគ្រីស្តជនត្រូវសងសឹកចំពោះមនុស្ស ដែលប្រព្រឹត្តអំពើអាក្រក់នៅពេលណា ?

☐ **មិនត្រូវសងសឹក ។**

☐ **ក្នុងករណីតឹងតែង ។**

សូមរកចំលើយនៅក្នុងបទគម្ពីរ រ៉ូម ១២:១៧ ។

© Project WorldReach © SEAN

១ កូរិនថូស ១៣:៦

"អ្នកមានចិត្តស្រឡាញ់...មិនអបអរនឹងអំពើទុច្ចរិតទេ តែរីករាយនឹងសេចក្តីពិតវិញ" ។



១ កូរិនថូស ១៣:៧

"អ្នកមានចិត្តស្រឡាញ់.....អត់ឱនអោយទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំងអស់ ហើយទ្រាំទ្រទាំងអស់" ។

យើងដែលមានចិត្តស្រឡាញ់ ត្រូវទ្រាំទ្រទាំងអស់ ទាំងនៅក្នុងក្រុមជំនុំ ទាំងក្នុងក្រុមគ្រួសារ ទាំងចំពោះអ្នកជិតខាង មនុស្សឯទៀត និង ចំពោះខ្មាំងសត្រូវ ។

អ្នកមានចិត្តស្រឡាញ់ ចេះទ្រាំទ្រទាំងអស់នៅក្នុងក្រុមជំនុំ

គ្រូគង្វាលដែលមានសេចក្តីស្រឡាញ់ចំពោះហ្វូងចៀមរបស់ខ្លួន តែងតែអត់ធ្មត់ស៊ូទ្រាំនឹងកំហុសជ័ច្រើនរបស់ហ្វូងចៀមនោះ ។

